ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០១៩/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីតុន ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
## ពីបោះតង់ ទៅជាសាងសង់ជម្រករឹងមាំ របស់យោធាវៀតណាម
## អាចរុញទំនាស់ព្រំដែន ធ្លាក់ក្នុងវិបត្តិធ្ងន់ធ្ងរ

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះស្ថានភាពកាន់តែអាក្រក់ នៅពេលការបោះតង់របស់កម្លាំងយោធាវៀតណាម នៅតាមតំបន់ព្រំដែន កំពុងក្លាយជាជម្រករឹងមាំ ដោយពុំទាន់មានដំណោះស្រាយត្រឹមត្រូវ ។

លិខិតរបស់លោក **ឈឿន សុចិត្ត** ស្នងការនគរបាលខេត្តកណ្តាល ជូនអភិបាលខេត្តកណ្តាល នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ បានអះអាងក្នុងកម្មវត្ថុ អំពីសកម្មភាពការពារព្រំដែនខេត្តអានយ៉ាង របស់វៀតណាម ប៉ុស្តិ៍៩២៥ វិញសឿង ដែលបានរុះរើតង់ចាស់ ដោយផ្លាស់ប្តូរសាងសង់តង់ថ្មី ជាជម្រករឹងមាំ ។ សំណង់ថ្មីរឹងមាំនេះ មានទីតាំងកៀកកិតស្ទើរជាប់នឹងភូមិក្អមសំណក្រោម ឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្តាល របស់កម្ពុជា ដោយឃ្លាតពីខ្សែបន្ទាត់ព្រំដែនទំនាស់បច្ចុប្បន្ន ចម្ងាយប្រមាណ១២០ម៉ែត្រប៉ុណ្ណោះ ។ លិខិតនេះពន្យល់ទៀតថា *«នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនក្អមសំណ យោធាការពារព្រំដែនកង៦០១ និងនាយប៉ុស្តិ៍ក្អមសំណ នៃភាគីខ្មែរ បានទៅជួបជាមួយប្រធានប៉ុស្តិ៍៩២៥វិញសឿង ខាងវៀតណាម ដើម្បីទាមទារឲ្យភាគីវៀតណាម បញ្ឈប់សកម្មភាពសាងសង់តង់ថ្មីនេះ ។ ប៉ុន្តែភាគីវៀតណាមបានបញ្ជាក់ថា គេធ្វើតាមបញ្ជាថ្នាក់លើរបស់គេ ហើយថ្នាក់លើរបស់គេ មានគម្រោងសាងសង់តង់ថ្មី (ជម្រករឹងមាំ) ចំនួន៤គោលដៅ លើ១០គោលដៅចាស់ ដែលមានស្រាប់»*។

សកម្មភាពបែបនេះរបស់យោធាវៀតណាម បង្ហាញអំពីមហិច្ឆតាឈ្លានពានរបស់ប្រទេសវៀតណាម គំរាមកំហែងមកលើប្រទេសកម្ពុជា មិនព្រលែងឡើយ ។ វៀតណាមចិញ្ចឹម នូវឧបាយកលបង្កើតបញ្ហាដល់ខ្មែរ នៅតាមតំបន់ព្រំដែនជាដរាប ហើយឆ្លៀតឱកាសកាត់ច្រៀកយកដីខ្មែរយកទៅគ្រប់គ្រង តាមវិធីកសាងសំណង់រឹងមាំថ្មីៗ ការធ្វើផ្លូវថ្មីៗ ឬការជីកព្រែកថ្មីៗ ជីកប្រឡាយថ្មីៗ រហូតដល់មានការបង្កើតភូមិវៀតណាម ចូលជ្រៅក្នុងទឹកដីកម្ពុជា ។ នៅតំបន់ខ្លះទៀតវៀតណាមបានចូលប្លន់ស្រស់ៗ យកដីស្រែចម្ការរបស់ប្រជាពលរដ្ឋខ្មែរ ធ្វើជាកម្មសិទ្ធិរបស់វៀតណាម ដូចជាទឹកដីខ្មែរផ្នែកខ្លះនៃតំបន់ដាក់ដាំ ខេត្តមណ្ឌលគីរី, ភូមិកំណើតរបស់លោក **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ហើយនិងបញ្ហាព្រំដែនមួយផ្នែក នៅក្នុងឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដែលនាំទៅដល់ការចាប់ឃុំខ្លួនលោក **រ៉ុង ឈុន**, លោក **សួង សុភ័ណ្ឌ**, យុវជន **ហ៊ុន វណ្ណៈ**, យុវតី **ឈឿន ដារ៉ាវី**, កញ្ញា **សភន្និភា** និងសកម្មជនមួយចំនួនទៀត ដោយបង្ខំ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចាត់ទុកថា ទឹកដីជាតិកម្ពុជា កាន់តែរអិលធ្លាក់ក្នុងស្ថានភាពអាសន្នរើមិនរួច នៅពេលដែលវៀតណាម កាន់តែបង្ហាញទង្វើឈ្លានពានបែបយោធា ដោយគ្មានញញើត ហើយអាជ្ញាធររដ្ឋាភិបាលកម្ពុជា ប្រឹងខ្ទប់សកម្មភាពការពារទឹកដីព្រំដែនជាតិរបស់ពលរដ្ឋខ្មែរ ដោយការធ្វើទុក្ខបុកម្នេញ ការចាប់ដាក់គុក និងគម្រាមដល់អាយុជីវិត ។

ទោះជាយ៉ាងណា ដោយសារវិបត្តិព្រំដែនជាតិកាន់តែធ្ងន់ធ្ងរ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** នៅតែជម្រុញរដ្ឋាភិបាលនៃលោក **ហ៊ុន សែន** ឲ្យប្រឹងប្រែងបង្ហាញជំហរបម្រើប្រយោជន៍ខ្មែរខ្លះ ដោយហ៊ានធ្វើលិខិតជូនដំណឹងអំពីការឈ្លានពានរបស់វៀតណាមនេះ ទៅកាន់សហប្រធានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលធានានូវបូរណភាពទឹកដីកម្ពុជា, អង្គការសហប្រជាជាតិ ដែលធានាឲ្យរដ្ឋនីមួយៗគោរពដែនអធិបតេយ្យគ្នា, និងសមាគមអាស៊ាន(ASEAN) ដែលតម្រូវឲ្យរដ្ឋសមាជិក *«គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់»* ។

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**អនុប្រធាន**

**អ៊ិប សេង**